ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភក្នុងក្របខ័ណ្ឌ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៣៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភក្នុងក្របខ័ណ្ឌនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (**អ.ជ.ក.**) សម្រាប់ផ្តល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ដែលរួមមាន ប្រធាន អនុប្រធាន និងសមាជិកនៃ **អ.ជ.ក.**, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.**, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្តនៃ **អ.ជ.ក.**, សមាជិកនៃក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ និងមន្ត្រីជាប់កិច្ចសន្យា ដែលបំពេញការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.**។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ដែលបម្រើការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.**។

## ជំពូកទី២
## ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភ

**មាត្រា៣ .-**

ថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ត្រូវទទួលបានប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភតាមការកំណត់ដូចខាងក្រោម ៖

**១. ថ្នាក់ដឹកនាំ និងសមាជិកនៃ អ.ជ.ក.**

| ល.រ. | បរិយាយ | ប្រាក់ឧបត្ថម្ភ (រៀល) ក្នុងមួយខែ |
|---|---|---|
| ១ | ប្រធាន **អ.ជ.ក.** | ២ ៥០០ ០០០ |
| ២ | អនុប្រធាន **អ.ជ.ក.** | ២ ៣០០ ០០០ |
| ៣ | សមាជិក **អ.ជ.ក.** | ២ ០០០ ០០០ |

**២. ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃ អ.ជ.ក.**

| ល.រ. | បរិយាយ | ប្រាក់ឧបត្ថម្ភ (រៀល) ក្នុងមួយខែ |
|---|---|---|
| ១ | អគ្គលេខាធិការ | ២ ០០០ ០០០ |
| ២ | អគ្គលេខាធិការរង | ១ ៥០០ ០០០ |

| | | |
|---|---|---|
| ៣ | ប្រធាននាយកដ្ឋាន | ១ ០០០ ០០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ១ ០០០ ០០០ |
| ៥ | ប្រធានការិយាល័យ | ១ ០០០ ០០០ |
| ៦ | អនុប្រធានការិយាល័យ | ១ ០០០ ០០០ |
| ៧ | មន្ត្រី | ១ ០០០ ០០០ |

៣. មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ មន្ត្រីជាប់កិច្ចសន្យា និងសមាជិកក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក.

| ល.រ. | បរិយាយ | ប្រាក់បំណាច់ (រៀល) ក្នុងមួយខែ | ប្រាក់ឧបត្ថម្ភ (រៀល) ក្នុងមួយថ្ងៃ |
|---|---|---|---|
| ១ | មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ជ.ក. | ២ ៥០០ ០០០ | |
| ២ | មន្ត្រីជាប់កិច្ចសន្យា | ១ ០០០ ០០០ | |
| ៣ | សមាជិកនៃក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ | | ៥០ ០០០ |

**មាត្រា៤ ..**

ថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ដែលទទួលបានការឧបត្ថម្ភលើកទឹកចិត្តពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬកម្មវិធីកែទម្រង់ផ្សេងទៀតរួចហើយ មិនអាចទទួលបានបន្ថែមនូវប្រាក់ឧបត្ថម្ភដូចមានកំណត់ក្នុងមាត្រា៣ ខាងលើ នោះទេ។

**មាត្រា៥ ..**

បន្ទាប់ពីត្រូវបានជ្រើសរើសជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.**, មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដែលកំណត់ដោយ **អ.ជ.ក.**។ នៅក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងចំនួនពាក់កណ្តាលនៃប្រាក់បំណាច់ប្រចាំខែសម្រាប់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ដូចមានកំណត់ក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ។

**មាត្រា៦ ..**

នៅពេលចុះបេសកកម្មបំពេញការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ប្រធាន អនុប្រធាន និងសមាជិកនៃ **អ.ជ.ក.**, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** និងមន្ត្រីជាប់កិច្ចសន្យា អាចទទួលបានរបបប្រាក់បេសកកម្ម ដោយអនុលោមតាមអនុក្រឹត្យស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នៅពេលចុះបេសកកម្មបំពេញការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្តនៃ **អ.ជ.ក.** ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រតិបត្តិការសម្រាប់ការចុះបំពេញបេសកកម្មនៅក្នុងប្រទេស។ ប្រាក់ឧបត្ថម្ភប្រតិបត្តិការនេះត្រូវបានកំណត់ដូចខាងក្រោម៖

- ប្រាក់ហោប៉ៅ ១៦ ០០០ រៀល ក្នុងមួយថ្ងៃ
- ប្រាក់ហូបចុក ៦០ ០០០ រៀល ក្នុងមួយថ្ងៃ

- ប្រាក់ស្នាក់នៅ ៨០ ០០០ រៀល ក្នុងមួយថ្ងៃ
- សោហ៊ុយធ្វើដំណើរ ៨០ ០០០ រៀល ក្នុងមួយរយគីឡូម៉ែត្រ សម្រាប់រថយន្តមួយគ្រឿង។

សមាជិកនៃក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទពុំត្រូវទទួលបាននូវប្រាក់ឧបត្ថម្ភប្រតិបត្តិការនោះទេ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១២ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.ជ.អ.**

**កើត រិទ្ធ**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ